ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# របាយការណ៍ត្រួតពិនិត្យកិច្ចលទ្ធកម្មសាធារណៈតាមក្រោយ ដែលស្ថិតក្រោមសិទ្ធិសម្រេច លើស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកា ប្រចាំឆ្នាំ២០១៦ លើការិយបរិច្ឆេទ២០១៥ របស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# របាយការណ៍ត្រួតពិនិត្យកិច្ចលទ្ធកម្មសាធារណៈតាមក្រោយ ដែលស្ថិតក្រោមសិទ្ធសម្រេច លើស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកា ប្រចាំឆ្នាំ២០១៦ សម្រាប់ការិយបរិច្ឆេទ ២០១៥ របស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៣៧៣📖៧៥៧

## ១.អំពីអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើបេសកកម្មគ្រប់គ្រងលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មានភារកិច្ចដូចតទៅ÷

- រៀបចំបង្កើត អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ត្រួតពិនិត្យនិងតាមដានលើរាល់កិច្ចលទ្ធកម្មសាធារណៈដែលអនុវត្តដោយស្ថាប័នអនុវត្តលទ្ធកម្ម
- ពិនិត្យនិងលើកយោបល់លើតារាងផែនការលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- ពិនិត្យនិងផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃ
- ពិនិត្យនិងលើកយោបល់លើសំណើសុំគោលការណ៍អនុវត្តវិធីសាស្ត្រនិងនីតិវិធីលទ្ធកម្ម
- ពិនិត្យនិងលើកយោបល់លើសំណើសុំប្រគល់កិច្ចសន្យាលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- គ្រប់គ្រងនិងតាមដានការអនុវត្តកិច្ចសន្យាលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- គ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ
- ចូលរួមដោះស្រាយវិវាទលទ្ធកម្ម
- បណ្តុះបណ្តាលអំពីការអនុវត្តវិធាននិងបទប្បញ្ញត្តិនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ដល់មន្ត្រីលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម មន្ត្រីពាក់ព័ន្ធដទៃទៀត អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ និងអ្នកទទួលការ។

## ២.រចនាសម្ព័ន្ធគ្រប់គ្រងរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មានរចនាសម្ព័ន្ធដូចខាងក្រោម÷

- នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ
- នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញ

- នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវា
- នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ
- នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ
- លេខាធិការដ្ឋាន។

**៣.តួនាទីនិងភារកិច្ចរបស់នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ**

នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈលើការងារត្រួតពិនិត្យនិងដោះស្រាយវិវាទពាក់ព័ន្ធលទ្ធកម្មសាធារណៈ។ នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ មានភារកិច្ចដូចខាងក្រោម÷

- រៀបចំផែនការត្រួតពិនិត្យកិច្ចលទ្ធកម្មប្រចាំឆ្នាំដាក់ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈពិនិត្យ និងសម្រេច
- ត្រួតពិនិត្យលើរាល់កិច្ចលទ្ធកម្មសាធារណៈ ដែលបានអនុវត្តរួចនិងស្ថិតក្រោមសិទ្ធសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- ធ្វើការត្រួតពិនិត្យផ្ទៃក្នុងលើនាយកដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈតាមការចាំបាច់
- ធ្វើរបាយការណ៍អំពីលទ្ធផលត្រួតពិនិត្យកិច្ចលទ្ធកម្មនៅរៀងរាល់ពេល នៃការចុះត្រួតពិនិត្យកិច្ចលទ្ធកម្មនិងរបាយការណ៍អំពីលទ្ធផលត្រួតពិនិត្យកិច្ចលទ្ធកម្មប្រចាំឆ្នាំ ដាក់ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ទទួលពាក្យបណ្តឹងតវ៉ាលទ្ធកម្ម
- ធ្វើការត្រួតពិនិត្យលើកិច្ចលទ្ធកម្មដែលមានទំនាស់
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការត្រួតពិនិត្យលើកិច្ចលទ្ធកម្មដែលមានទំនាស់ ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- សហការជាមួយស្ថាប័នអនុវត្តលទ្ធកម្មលើការងារដោះស្រាយបណ្តឹងតវ៉ានិងវិវាទលទ្ធកម្ម
- សម្របសម្រួលជាមួយនាយកដ្ឋាន បុគ្គលិក និងផែនការ នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈដើម្បីផ្សព្វផ្សាយលទ្ធផលនៃការដោះស្រាយបណ្តឹងតវ៉ានិងវិវាទលទ្ធកម្មតាមរយៈគេហទំព័រលទ្ធកម្មសាធារណៈ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ ប្រចាំខែត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- បំពេញភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ មានការិយាល័យក្រោមឱវាទចំនួន៤ ដូចខាងក្រោម÷

- ការិយាល័យត្រួតពិនិត្យលទ្ធកម្មរដ្ឋបាលថ្នាក់ជាតិ
- ការិយាល័យត្រួតពិនិត្យលទ្ធកម្មរដ្ឋបាលរាជធានី ខេត្ត
- ការិយាល័យត្រួតពិនិត្យលទ្ធកម្មអង្គភាពស្វយ័ត
- ការិយាល័យអធិការកិច្ចនិងដោះស្រាយវិវាទលទ្ធកម្ម។

## ៤.គោលបំណងនៃការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ

- ពង្រឹងបន្ថែមនិងកែលម្អលើការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់ស្ថាប័នអនុវត្តលទ្ធកម្ម និង អង្គភាពថវិកា
- បង្កើនទំនុកចិត្តពីសំណាក់ភាគីពាក់ព័ន្ធរួមទាំងសាធារណៈជនលើប្រព័ន្ធលទ្ធកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា
- ពង្រឹងការទទួលខុសត្រូវរបស់មន្ត្រីនិងថ្នាក់ដឹកនាំនៃស្ថាប័នអនុវត្តលទ្ធកម្មនិងអង្គភាពថវិកាក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ
- ដាក់ពិន័យមន្ត្រីលទ្ធកម្មសាធារណៈដែលប្រព្រឹត្តល្មើសនឹងវិធាន និងបទប្បញ្ញត្តិលទ្ធកម្មសាធារណៈ។

## ៥. វិសាលភាពនៃការត្រួតពិនិត្យនិងវិធីសាស្ត្រត្រួតពិនិត្យ

ការត្រួតពិនិត្យកិច្ចលទ្ធកម្មដែលបានអនុវត្តរួចនិងស្ថិតក្រោមសិទ្ធិសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្មនិងអង្គភាពថវិកា នៅការិយបរិច្ឆេទនៃឆ្នាំកន្លងទៅ។ ការត្រួតពិនិត្យធ្វើឡើងដោយផ្អែកលើកិច្ចសន្យាដែលបានជ្រើសរើសជាគំរូ ហើយការត្រួតពិនិត្យអនុវត្តចាប់ពីដំណាក់កាលធ្វើផែនការលទ្ធកម្មរហូតដល់ចុងបញ្ចប់នៃកិច្ចលទ្ធកម្ម និងគ្រប់ផ្នែកពាក់ព័ន្ធ។

វិធីសាស្ត្រនៃការត្រួតពិនិត្យកិច្ចលទ្ធកម្មដែលបានអនុវត្តរួច ធ្វើឡើងដើម្បី÷

- កំណត់កម្រិតហានិភ័យរបស់ស្ថាប័នអនុវត្តលទ្ធកម្មនិងអង្គភាពថវិកា
- ពិនិត្យសំណុំឯកសារលទ្ធកម្មនិងឯកសារពាក់ព័ន្ធ
- សម្ភាសន៍ជាមួយមន្ត្រីពាក់ព័ន្ធ (សាកសួរប្រភពផ្សេងៗ)
- អង្កេតដំណើរការលទ្ធកម្មនៅគ្រប់ដំណាក់កាល
- ជ្រើសរើសកិច្ចសន្យាគំរូសម្រាប់ត្រួតពិនិត្យ
- ពិនិត្យភស្តុតាងជាក់ស្តែង (ប្រគល់-ទទួល)
- កំណត់បញ្ហាប្រឈម។ល។

**៥.កិច្ចប្រតិបត្តិការត្រួតពិនិត្យកិច្ចលទ្ធកម្មសាធារណៈស្ថិតក្រោមសិទ្ធិសម្រេច**

នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ បានចុះត្រួតពិនិត្យកិច្ចលទ្ធកម្មសាធារណៈស្ថិតក្រោមសិទ្ធិសម្រេចក្នុងឆ្នាំ២០១៦ (លើការិយបរិច្ឆេទ២០១៥) បានចំនួនសរុប១១៨ស្ថាប័ន ស្មើនឹង៨៤.៨៩ភាគរយនៃផែនការត្រួតពិនិត្យប្រចាំឆ្នាំដូចមានក្នុងតារាងខាងក្រោម៖

**៥.១.ចំនួនស្ថាប័នដែលបានចុះត្រួតពិនិត្យធៀបនឹងផែនការ**

| ការិយាល័យត្រួតពិនិត្យកិច្ចលទ្ធកម្ម | ផែនការត្រួតពិនិត្យឆ្នាំ២០១៦ | ចំនួនស្ថាប័នត្រួតពិនិត្យ | ចំនួនស្ថាប័នមិនបានត្រួតពិនិត្យ |
|---|---|---|---|
| រដ្ឋបាលថ្នាក់ជាតិ | ២៩ | ២៣ | ៦ |
| រដ្ឋបាលរាជធានី-ខេត្ត | ២៥ | ២៥ | 0 |
| អង្គភាពស្វយ័ត | ៣៩ | ៣៩ | 0 |
| អធិការកិច្ច និងដោះស្រាយវិវាទលទ្ធកម្ម | ៤៦ | ៣១ | ១៥ |
| សរុប | ១៣៩ | ១១៨ | ២១ |

**បញ្ជាក់:**

ស្ថាប័នចំនួន២១ដែលមិនបានត្រួតពិនិត្យតាមផែនការប្រចាំឆ្នាំ ដោយសារមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីចុះត្រួតពិនិត្យ។

**៥.២.ស្ថាប័នដែលបានអនុវត្តកិច្ចលទ្ធកម្មស្របទៅនឹងផែនការលទ្ធកម្ម មានដូចខាងក្រោម៖**

| | |
|---|---|
| ស្ថាប័នអនុវត្តលទ្ធកម្ម (ថ្នាក់ជាតិ) | ១.ក្រសួងយុត្តិធម៌ |
| | ២.ក្រសួងសាធារណការនិងដឹកជញ្ជូន |
| ស្ថាប័នអនុវត្តលទ្ធកម្ម (អង្គភាពស្វយ័ត) | ១.វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| | ២.បេឡាជាតិរបបសន្តិសុខសង្គម |
| | ៣.អាជ្ញាធរទន្លេសាប |
| | ៤.គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ |
| | ៥.មន្ទីរពេទ្យព្រះអង្គឌួង |
| | ៦.មជ្ឈមណ្ឌលពិសោធន៍សុខាភិបាល |
| | ៧.វិទ្យាស្ថានជាតិសុខភាពសាធារណៈ |
| | ៨.មន្ទីរពេទ្យកុមារជាតិ |
| | ៩.វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា |

| | |
|---|---|
| | ១០.ប្រៃសណីយ៍កម្ពុជា |
| | ១១.ភ្នាក់ងារកម្ពុជានាវាចរណ៍ |
| | ១២. សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ |
| | ១៣. អាជ្ញាធរជាតិប្រយុទ្ធនិងជម្ងឺអេដស៍ |
| | ១៤. មន្ទីរពេទ្យកាល់ម៉ែត |
| | ១៥. សាលាជាតិកសិកម្មព្រែកលៀប |
| | ១៦. តុលាការកំពូលនិងមហាអយ្យការអមតុលាការកំពូល |
| | ១៧. សាលាឧទ្ធរណ៍ |
| | ១៨. សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| | ១៩.វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា |
| | ២០. បេឡាជាតិអតីតយុទ្ធជន |
| | ២១. គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា |
| **ស្ថាប័នអនុវត្តលទ្ធកម្ម (រាជធានី ខេត្ត)** | ១.ខេត្តព្រៃវែង |
| **ស្ថាប័នអនុវត្តលទ្ធកម្ម (ក្រុងស្រុកខណ្ឌ)** | ១.ស្រុកស្វាយជ្រំ |
| | ២.ស្រុកត្បែងមានជ័យ |
| | ៣.ស្រុកសំរោងទុង |
| | ៤.ក្រុងស្ទឹងសែន |
| | ៥.ស្រុកពាមរក៍ |
| | ៦.ស្រុកត្បូងឃ្មុំ |
| | ៧.ស្រុកបារាយណ៍ |
| | ៨.ខណ្ឌដង្កោ |
| | ៩.ខណ្ឌឫស្សីកែវ |
| | ១០.ខណ្ឌដូនពេញ |
| | ១១.ខណ្ឌព្រែកព្នៅ |
| | ១២.ខណ្ឌមានជ័យ |
| | ១៣.ខណ្ឌចំការមន |
| | ១៤.ខណ្ឌ៧មករា |
| | ១៥.ខណ្ឌច្បារអំពៅ |
| | ១៦.ខណ្ឌពោធិ៍សែនជ័យ |
| | ១៧.ខណ្ឌសែនសុខ |

| | |
|---|---|
| | ១៨.ខណ្ឌទួលគោក |
| | ១៩.ខណ្ឌជ្រោយចង្វារ |
| | ២០.ក្រុងពោធិ៍សាត់ |
| | ២១.ស្រុកកណ្ដៀង |
| | ២២.ក្រុងសួង |

**៥.៣.ស្ថាប័នអនុវត្តលទ្ធកម្មដែលបានអនុវត្តកិច្ចលទ្ធកម្មតិចជាងផែនការលទ្ធកម្មមានដូចខាងក្រោម៖**

| | |
|---|---|
| ស្ថាប័នអនុវត្តលទ្ធកម្ម (ថ្នាក់ជាតិ) | ១.ក្រសួងពាណិជ្ជកម្ម |
| | ២.ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| | ៣.រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល |
| | ៤.ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| | ៥.ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | ៦.ក្រសួងផែនការ |
| | ៧.ក្រសួងអប់រំយុវជន និងកីឡា |
| | ៨.ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| | ៩.ក្រសួងរ៉ែ និងថាមពល |
| | ១០.ក្រសួងទេសចរណ៍ |
| | ១១.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត |
| | ១២.ក្រសួងមុខងារសាធារណៈ |
| | ១៣.ទីស្ដីការគណៈរដ្ឋមន្ត្រី |
| ស្ថាប័នអនុវត្តលទ្ធកម្ម (អង្គភាពស្វយ័ត) | ១.ក្រុមហ៊ុនហ្រ្គីនត្រេដ |
| | ២.សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| | ៣.ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម |
| | ៤.ធនាគារអភិវឌ្ឍន៍ជនបទ |
| | ៥.កំពង់ផែស្វយ័តភ្នំពេញ |
| | ៦.កំពង់ផែស្វយ័តក្រុងព្រះសីហនុ |
| | ៧.ទូរគមនាគមន៍កម្ពុជា |
| | ៨.រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| | ៩.មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត |
| | ១០.និយតករទូរគមនាគមន៍កម្ពុជា |

| | |
|---|---|
| | ១១.រដ្ឋាករទឹកស្វយ័តសៀមរាប |
| | ១២.មន្ទីរពេទ្យព្រះកុសុមៈ |
| ស្ថាប័នអនុវត្តលទ្ធកម្ម (រាជធានី ខេត្ត) | ១.ខេត្តសៀមរាប |
| | ២.ខេត្តព្រះវិហារ |
| | ៣.ខេត្តស្វាយរៀង |
| | ៤.ខេត្តកណ្តាល |
| | ៥.ខេត្តកំពង់ចាម |
| ស្ថាប័នអនុវត្តលទ្ធកម្ម (ក្រុងស្រុកខណ្ឌ) | ១.ស្រុកកូលែន |
| | ២.ស្រុកកំពង់ត្រឡាច |
| | ៣.ក្រុងបាត់ដំបង |
| | ៤.ស្រុករលាប្អៀរ |
| | ៥.ក្រុងច្បារមន |
| | ៦.ក្រុងកំពង់ឆ្នាំង |
| | ៧.ក្រុងដូនកែវ |
| | ៨.ស្រុកទ្រាំង |

***សម្គាល់:***

ការអនុវត្តបានតិចជាងផែនការលទ្ធកម្ម ដោយស្ថាប័នអនុវត្តលទ្ធកម្មមួយចំនួនច្របាច់បញ្ចូលគម្រោងកិច្ចលទ្ធកម្មជាមួយគ្នា ហើយអនុវត្តកិច្ចលទ្ធកម្មតែមួយលើកនិងមិនបានធ្វើផែនការលទ្ធកម្មកែតម្រូវ ឬគ្មានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចលទ្ធកម្ម។

**៥.៤.ស្ថាប័នអនុវត្តលទ្ធកម្ម ដែលអនុវត្តកិច្ចលទ្ធកម្មលើសផែនការលទ្ធកម្ម មានដូចខាងក្រោម៖**

| | |
|---|---|
| ស្ថាប័នអនុវត្តលទ្ធកម្ម (ថ្នាក់ជាតិ) | ១.ក្រសួងបរិស្ថាន |
| | ២.ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| | ៣.ក្រសួងអភិវឌ្ឍន៍ជនបទ |
| | ៤.ក្រសួងព័ត៌មាន |
| | ៥.ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា |
| | ៦.ក្រសួងធម្មការនិងសាសនា |
| | ៧.ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| | ៨.ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ |
| ស្ថាប័នអនុវត្តលទ្ធកម្ម (អង្គភាពស្វយ័ត) | ១.មូលនិធិជនពិការ |

| | |
|---|---|
| | ២.សាលាជាតិកសិកម្មកំពង់ចាម |
| | ៣.អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន |
| | ៤.សាកលវិទ្យាល័យជាតិគ្រប់គ្រង |
| | ៥.បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល |
| | ៦.អគ្គិសនីកម្ពុជា |
| ស្ថាប័នអនុវត្តលទ្ធកម្ម (រាជធានី ខេត្ត) | ១.ខេត្តរតនគិរី |
| | ២.ខេត្តស្ទឹងត្រែង |
| | ៣.ខេត្តត្បូងឃ្មុំ |
| | ៤.ខេត្តប៉ៃលិន |
| | ៥.ខេត្តបន្ទាយមានជ័យ |
| | ៦.ខេត្តកោះកុង |
| | ៧.ខេត្តព្រះសីហនុ |
| | ៨.ខេត្តឧត្តមានជ័យ |
| | ៩.ខេត្តកំពត |
| | ១០.ខេត្តកែប |
| | ១១.រាជធានីភ្នំពេញ |
| | ១២.ខេត្តតាកែវ |
| | ១៣.ខេត្តមណ្ឌលគិរី |
| | ១៤.ខេត្តកំពង់ធំ |
| | ១៥.ខេត្តក្រចេះ |
| | ១៦.ខេត្តកំពង់ឆ្នាំង |
| | ១៧.ខេត្តពោធិ៍សាត់ |
| | ១៨.ខេត្តកំពង់ស្ពឺ |
| | ១៩.ខេត្តបាត់ដំបង |
| ស្ថាប័នអនុវត្តលទ្ធកម្ម (ក្រុងស្រុកខណ្ឌ) | ១.ស្រុកសង្កែ |

**សម្គាល់:**

ស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មលើសគម្រោងក្នុងផែនការលទ្ធកម្មច្រើនជាងគេគឺស្ថាប័នអនុវត្តលទ្ធកម្មរដ្ឋបាលរាជធានីខេត្តដោយ÷

- នៅឆមាសទី២ ឆ្នាំ២០១៥ មន្ទីរជំនាញមួយចំនួនក្នុងចំណោមមន្ទីរជំនាញទាំង១០ដែលបានអនុវត្ត ថវិកាកម្មវិធីបានអនុវត្តកិច្ចលទ្ធកម្មដោយខ្លួនឯង
- ការអនុវត្តកិច្ចលទ្ធកម្មដោយមិនបានធ្វើផែនការកែតម្រូវតាមតម្រូវការចាំបាច់របស់ខ្លួន
- ធ្វើផែនការកែតម្រូវដែរ ប៉ុន្តែមិនអនុវត្តតាមផែនការកែតម្រូវនោះដោយបំបែកធានាចំណាយជាគម្រោងតូចៗតម្រូវតាម សិទ្ធិសម្រេចរបស់ស្ថាប័នខ្លួន។

## ៦.គោលបំណងនៃការផ្សព្វផ្សាយ

ការផ្សព្វផ្សាយរបាយការណ៍ត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយជាសាធារណៈ មានគោលបំណងចូលរួមចំណែកជាមួយស្ថាប័នអនុវត្តលទ្ធកម្ម ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងារលទ្ធកម្មរបស់ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលក្រុងស្រុកខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ និងអង្គភាពពាក់ព័ន្ធនានាតាមរយៈការចង្អុលបង្ហាញនូវចំណុចខ្វះខាតក្នុងការអនុវត្តកិច្ចលទ្ធកម្មកន្លងមក និងផ្តល់អនុសាសន៍កែលម្អលើចំណុចខ្វះខាតទាំងនោះ សំដៅធ្វើឱ្យការអនុវត្តកិច្ចលទ្ធកម្មកាន់តែមានភាពប្រសើរឡើង។

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ និងអង្គភាព ពាក់ព័ន្ធនានាក្នុងករណីដែលមានតតិយជនទាំងឡាយណាយកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈនេះទៅធ្វើការបកស្រាយ ឬប្រើប្រាស់ខុសគោលដៅឡើយ។

## ៧. លទ្ធផលនៃការរកឃើញនៃការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយតាមដំណាក់កាល

### ៧.១ ការអនុវត្តផែនការលទ្ធកម្ម

ស្ថាប័នអនុវត្តលទ្ធកម្មរដ្ឋបាលរាជធានីខេត្តមួយចំនួន អនុវត្តកិច្ចលទ្ធកម្មលើសគម្រោងផែនការលទ្ធកម្មដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយសារមន្ទីរជំនាញមួយចំនួន (អង្គភាពថវិកា) បានអនុវត្តកិច្ចលទ្ធកម្មដោយមិនបានស្នើសុំកែតម្រូវផែនការលទ្ធកម្មតាមតម្រូវការចាំបាច់របស់ខ្លួនឡើយ។ ស្ថាប័នអនុវត្តលទ្ធកម្មនៃរដ្ឋបាលរាជធានីខេត្តមួយចំនួនទៀត បានបំបែកគម្រោងទៅជាគម្រោងតូចៗដើម្បីតម្រូវតាមសិទ្ធិសម្រេចរបស់ស្ថាប័នខ្លួន។

### ៧.២ ការរៀបចំឯកសារស្នើសុំធានាចំណាយ

ស្ថាប័នអនុវត្តលទ្ធកម្មមួយចំនួនរៀបចំឯកសារស្នើសុំធានាចំណាយមិនបានត្រឹមត្រូវតាមនីតិវិធីឡើយ ក្នុងនោះមានស្ថាប័នអនុវត្តលទ្ធកម្មមួយចំនួនមិនបានរៀបចំបញ្ជីប៉ាន់-តម្លៃ លក្ខណៈបច្ចេកទេស និងប្រភពទំនិញឱ្យបានច្បាស់លាស់ដើម្បីភ្ជាប់សំណើសុំធានាចំណាយ។

### ៧.៣ ការអនុវត្តវិធីសាស្ត្រលទ្ធកម្ម

ស្ថាប័នអនុវត្តលទ្ធកម្មភាគច្រើនបានអនុវត្តវិធីសាស្ត្រលទ្ធកម្មសមស្របតាមកម្រិតទឹកប្រាក់ដែលបានកំណត់ដោយច្បាប់។ ដោយឡែក ចំពោះការអនុវត្តកិច្ចលទ្ធកម្មដោយឡែកមានស្ថាប័នអនុវត្តលទ្ធកម្មមួយចំនួនមិនបានស្នើសុំគោលការណ៍ជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមួយចំនួនទៀតបានស្នើសុំគោលការណ៍ដែរប៉ុន្តែមិនបានឆ្លងការសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ៧.៤ ការរៀបចំឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃ

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈបានរកឃើញថា ការរៀបចំឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃរបស់ស្ថាប័នអនុវត្តលទ្ធកម្មមួយចំនួននៅមានចំណុចខ្វះចន្លោះនៅឡើយ ក្នុងនោះរួមមានៈ ខ្លឹមសារនៃសេចក្តីណែនាំចំពោះអ្នកដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃមិនស្របតាមគំរូដែលបានផ្តល់ជូនដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការកោសលុប ឬសរសេរបន្ថែមខុសពីគំរូឯកសារដើម។ សមាសភាពឯកសារស្ទង់តម្លៃមិនមានភ្ជាប់សេចក្តីជូនដំណឹងស្តីពីការអញ្ជើញឱ្យចូលរួមស្ទង់តម្លៃ និងសេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មរបស់អ្នកស្ទង់តម្លៃជាដើម។ ជាងនេះទៀត ពាក្យសុំដេញថ្លៃ និងពិគ្រោះថ្លៃមួយចំនួនត្រូវបានគេបំពេញរយៈពេលសុពលភាពជំនួសអ្នកដេញថ្លៃរួចជាស្រេច និងមិនមានភ្ជាប់នូវគំនូសប្លង់ និងការ-លម្អិតលក្ខណៈបច្ចេកទេស និងប្រតិទិនការងារជាដើម។

## ៧.៥ ការផ្សព្វផ្សាយលក់ ទទួល និងបើកសំណើដេញថ្លៃ

ស្ថាប័នអនុវត្តលទ្ធកម្មមួយចំនួនបានធ្វើការផ្សព្វ-ផ្សាយលក់ទទួល និងបើកសំណើដេញថ្លៃមិនបានត្រឹមត្រូវតាមនីតិវិធីកំណត់ដូចជាៈ ការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការអញ្ជើញឱ្យចូលរួមដេញថ្លៃពិគ្រោះថ្លៃតាមសារព័ត៌មានធ្វើឡើងតែមួយលើក និងផ្សាយក្រោយកាលបរិច្ឆេទលក់ឯកសារ។ ការផ្សព្វផ្សាយមានរយៈពេលខ្លីមិនស្របតាមច្បាប់កំណត់ និងមិនបានធ្វើតារាងកត់ត្រាបញ្ជីលក់/ប្រគល់ឯកសារ និងទទួលសំណើដេញថ្លៃ ឬកត់ត្រានៅថ្ងៃតែមួយ ហើយក្រុមហ៊ុនមួយចំនួនមិនបានចេញលិខិតផ្ទេរសិទ្ធិឱ្យតំណាងចូលរួមបើកសំណើដេញថ្លៃ និងពិគ្រោះថ្លៃជាដើម។ ស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកាមួយចំនួនមិនបានធ្វើបច្ចុប្បន្នភាពកំណត់ហេតុបើកសំណើដេញថ្លៃ ឱ្យស្របតាមគំរូបទដ្ឋានដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមួយចំនួនទៀតពុំបានភ្ជាប់អគ្រាប្បូរប្រាក់ ពុំមាន/មានលិខិតធានាប្រាក់កក់ធានាការដេញថ្លៃនិងបានចុះកាលបរិច្ឆេទដូចគ្នា និងលេខរៀងបន្តបន្ទាប់គ្នា។ មួយវិញទៀត គណៈកម្មការបើកសំណើដេញថ្លៃ និងពិគ្រោះថ្លៃមួយចំនួនពុំបានចុះហត្ថលេខាលើពាក្យសុំ ឬបញ្ជីប៉ាន់តម្លៃសរុបរបស់ក្រុមហ៊ុន។ សំណើដេញថ្លៃមួយចំនួនមានសុពលភាពខ្លីជាងការកំណត់ដែលមិនស្របតាម សេចក្តីណែនាំចំពោះអ្នកចូលរួមដេញថ្លៃ ហើយក្រុមហ៊ុនចូលរួមដេញថ្លៃមួយចំនួនពុំបានបំពេញសុពលភាពលើសំណើដេញថ្លៃរបស់ខ្លួន និងមិនមានបញ្ជីវត្តមានក្នុងពេលបើកសំណើដេញថ្លៃ និងការផ្សព្វផ្សាយអញ្ជើញឱ្យចូលរួមដេញថ្លៃធ្វើឡើងមុនការផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃជាដើម។

### ៧.៦ ការវាយតម្លៃប្រគល់កិច្ចសន្យា

មានស្ថាប័នអនុវត្តលទ្ធកម្មមួយចំនួនបង្កើតលក្ខខណ្ឌវាយតម្លៃថ្មី មិនស្របតាមគំរូដែលបានផ្ដល់ជូនដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ស្ថាប័នអនុវត្តលទ្ធកម្មមួយចំនួនទៀតបានវាយ-តម្លៃលើភាពឆ្លើយតបមិនបានត្រឹមត្រូវតាមព័ត៌មានជាក់ស្ដែង និងពុំបានធ្វើតារាងប្រៀបធៀបតម្លៃទីផ្សារនៃសមាធាតុលទ្ធកម្មដែលជាមូលដ្ឋានសម្រាប់ការវាយតម្លៃ។ ចំពោះលិខិតសម្រេចជ្រើសរើសនិងប្រគល់កិច្ចសន្យា ស្ថាប័នអនុវត្តលទ្ធកម្មពុំបានចម្លងជូនគ្រប់ភាគីអ្នកដេញថ្លៃ និងទុកពេលវេលាខ្លីជាង១០ថ្ងៃសម្រាប់អ្នកចូលរួមដេញថ្លៃធ្វើការប្ដឹងតវ៉ាទៅនឹងលទ្ធផលនៃការដេញថ្លៃ និងពិគ្រោះថ្លៃ។ ទោះបីជាក្រុមហ៊ុនដែលបានចូលរួមដេញថ្លៃ និងពិគ្រោះមួយចំនួនមិនបានភ្ជាប់ ឬគ្មានអត្តសញ្ញាណប័ណ្ណប្រជាជន វិញ្ញាបនបត្រ បញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម (ក្រសួងពាណិជ្ជកម្ម) វិញ្ញាបនបត្រប្រកបអាជីវកម្មចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម និងវិញ្ញាបនបត្រចុះបញ្ជីអ្នកទទួលការសាងសង់ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ប៉ុន្តែគណៈកម្មាធិការលទ្ធកម្មនៅតែប្រគល់កិច្ចសន្យាជូន។ ស្ថាប័នអនុវត្តលទ្ធកម្មមួយចំនួន (ក្រុង ស្រុក ខណ្ឌ) បានចេញលិខិតអញ្ជើញក្រុមហ៊ុនឱ្យចូលរួមចរចាថ្លៃមុនមានលិខិតអនុញ្ញាតរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងពុំបានរៀបចំតារាងលេខគណិតឡើងវិញលើតម្លៃដាក់ដេញរបស់ក្រុមហ៊ុនដែលចូលរួមដេញថ្លៃឡើយ។

### ៧.៧ ការចុះកិច្ចសន្យា

ស្ថាប័នអនុវត្តលទ្ធកម្មមួយចំនួនបានរៀបចំកិច្ចសន្យាមិនបានត្រឹមត្រូវដោយមិនបានបញ្ជាក់ពីកាលបរិច្ឆេទនៃការចាប់ផ្ដើម និងបញ្ចប់ការងារ ការប្រគល់ទទួល ការធានាលើសេវាប្រើប្រាស់ទំនិញ និងការទូទាត់ពុំបានបញ្ជាក់ឱ្យបានច្បាស់លាស់។ លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិពុំមានបញ្ជាក់សុពលភាព ហើយការតក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាគឺធ្វើឡើងក្រោយកិច្ចសន្យាចូលជាធរមាន និងកិច្ចសន្យាមួយចំនួនពុំមានភ្ជាប់តារាងឧបសម្ព័ន្ធ និងបញ្ជាក់អំពីរយៈពេលធានាគុណភាពសំណង់ឡើយ។

### ៧.៨ ការអនុវត្តកិច្ចសន្យា និងការប្រគល់ទទួល

អគ្គនាយកដ្ឋានកម្មសាធារណៈបានរកឃើញថា ស្ថាប័នអនុវត្តលទ្ធកម្មមួយចំនួនអនុវត្តការងារប្រគល់ទទួលបញ្ចប់សុពលភាពសំណង់ ដោយមិនមានកំណត់ហេតុបញ្ចប់សុពលភាពនិងពុំមានការចាត់តាំងគណៈកម្មការតាមដានត្រួតពិនិត្យការអនុវត្តគម្រោង (ការងារសំណង់) និងមិនមានរបាយការណ៍ស្ដីពីវឌ្ឍនភាពនៃការអនុវត្តការងារ។ រីឯទម្រង់និងខ្លឹមសារកំណត់ហេតុប្រគល់ទទួលមិនទាន់បានធ្វើបច្ចុប្បន្នភាពឱ្យស្របតាមគំរូណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគម្រោងខ្លះមិនមានកំណត់ហេតុប្រគល់ទទួលប៉ុន្តែ

មានលិខិតបញ្ជាក់ពីភូមិឃុំថាបានអនុវត្តការងាររួចរាល់។ មួយវិញទៀត រយៈពេលនៃការអនុវត្តកិច្ចសន្យានៃគម្រោងមួយចំនួនមានរយៈពេលខ្លីមិនស្របទៅនឹងទំហំការងារឡើយ។

**៧.៩ ការត្រួតពិនិត្យលទ្ធផលនៃការប្រគល់ទទួលជាក់ស្តែង**

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈបានរកឃើញថា ស្ថាប័នអនុវត្តលទ្ធកម្មមួយចំនួនមិនបានធ្វើការប្រគល់ទទួលបញ្ចប់សុពលភាពសំណង់ឱ្យបានទាន់ពេលវេលាឡើយ ហើយស្ថាប័នអនុវត្តលទ្ធកម្មមិនមានវិធានការផាកពិន័យចំពោះក្រុមហ៊ុនដែលប្រគល់ទំនិញ ឬសំណង់យឺតជាងកាលកំណត់ឡើយ។ គម្រោងមួយចំនួនមិនបានបញ្ជាក់ឱ្យបានច្បាស់លាស់អំពីលក្ខណៈបច្ចេកទេស និងគំនូសប្លង់ និងករណីខ្លះទៀតសំណង់បានធ្វើឡើងមុនកិច្ចសន្យាចូលជាធរមាន ព្រមទាំងមានការកែសម្រួលសំណង់ឡើងវិញក្រោយពេលប្រតិភូបានពិនិត្យឃើញនូវចំណុចខ្វះខាត។

**៧.១០ ការដោះស្រាយបណ្តឹងតវ៉ា**

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈបានចុះពិនិត្យស្រាវជ្រាវឯកសារនានាលើការប្តឹងតវ៉ារបស់ក្រុមហ៊ុន ឌី អិម ហ្គោលដេន ខនស្ត្រាក់សិន ឯ.ក ចំពោះការសម្រេចចិត្តរបស់គណៈកម្មាធិ-ការលទ្ធកម្មស្រុកគីរីវង្សដែលបានសម្រេចវាយតម្លៃប្រគល់កិច្ចសន្យាជូន ក្រុមហ៊ុនសំណង់យេ-ធី ដែលមានតម្លៃពិគ្រោះថ្លៃទាបជាងគេប៉ុន្តែពុំស្របតាមលក្ខខណ្ឌវិនិច្ឆ័យដែលមានចែងក្នុងឯកសារពិគ្រោះថ្លៃនិងគោលការណ៍ណែនាំសម្រាប់ការវាយតម្លៃប្រគល់កិច្ចសន្យា។ ជាលទ្ធផលនៃការដោះស្រាយបណ្តឹងតវ៉ានេះ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈបានលើកសំណើសុំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចេញលិខិតជូនដល់គណៈកម្មាធិការលទ្ធកម្មស្រុកគីរីវង្សឱ្យពិចារណាវាយតម្លៃឡើងវិញ និងប្រគល់កិច្ចសន្យាឱ្យទៅក្រុមហ៊ុនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្តកិច្ចសន្យា។

**៨. ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តន៍តាមអនុសាសន៍**

ជាទូទៅស្ថាប័នអនុវត្តលទ្ធកម្មបានឆ្លើយបំភ្លឺ និងទទួលយកនូវចំណុចខ្វះខាត ដែលប្រតិភូត្រួតពិនិត្យនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈបានរកឃើញ និងសន្យាពង្រឹងការអនុវត្តកិច្ចលទ្ធកម្មរបស់ខ្លួនឱ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធស្តីពីលទ្ធកម្មសាធារណៈនានា ដែលស្ថិតនៅជាធរមានក្នុងការអនុវត្តកិច្ចលទ្ធកម្មនាការិយបរិច្ឆេទក្រោយៗទៀត។

**៩. សេចក្តីសន្និដ្ឋាន**

ឆ្លងតាមរយៈការអនុវត្តការងារត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ (ស្ថិតក្រោមសិទ្ធិសម្រេចឆ្នាំ២០១៦ លើការិយបរិច្ឆេទឆ្នាំ២០១៥) លើស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកាចំនួន១១៨ស្ថាប័ននេះ អគ្គនាយកដ្ឋានសាធារណៈបានសង្កេតឃើញថា ការអនុវត្តវិធីសាស្ត្រលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកាមានលក្ខណៈល្អប្រសើរជាងបណ្តាឆ្នាំកន្លងទៅ ទោះបីនៅមានកំហុសឆ្គងមួយចំនួន ប៉ុន្តែវឌ្ឍនភាពការងារ

នៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅតាមបណ្តាស្ថាប័នអនុវត្តលទ្ធកម្មនានាមានភាពល្អប្រសើរជាងបណ្តាឆ្នាំកន្លងទៅ ដោយសារលិខិតបទដ្ឋានគតិយុត្តិស្តីពីលទ្ធកម្មសាធារណៈត្រូវបានកែសម្រួលនិងធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ស្របតាមតម្រូវការនិងស្ថានភាពជាក់ស្តែង ហើយមន្ត្រីនៃអង្គភាពលទ្ធកម្ម/ក្រុមលទ្ធកម្មភាគច្រើនបានចូលរួមវគ្គបណ្តុះបណ្តាលជំនាញលទ្ធកម្មសាធារណៈ ដែលបានរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនាពេលកន្លងមក ជាពិសេសថ្នាក់ដឹកនាំនៃស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកាមួយចំនួនមានឆន្ទៈក្នុងការកែលម្អនូវចំណុចខ្វះខាត ដែលប្រតិភូត្រួតពិនិត្យនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈបានរកឃើញនិងផ្តល់អនុសាសន៍ជូន។